ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្ដីពី

## លទ្ធផលការងាររបស់ព្រឹទ្ធសភា

## ប្រចាំខែកញ្ញា ឆ្នាំ២០១៧

នៅក្នុងខែកញ្ញា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទីចំនួន០១លើក

-អនុញ្ញាតជូនឯកឧត្តម **ប្រាយុទ្ធ ច័ន្ទអូចា** (Prayaut Chan-o-cha) នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃឡង់ដ៍ និងគណៈប្រតិភូ ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតជូនឯកឧត្តម Wang Jiarui អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតជូនឯកឧត្តម **ហ័ង ជុងហាយ** សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ដវៀតណាម និងជាលេខាគណៈកម្មាធិការបក្សរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតជូនលោកជំទាវ **ង្វៀន ធីធូហា** សមាជិកគណៈកម្មាធិការកណ្ដាលមជ្ឈិមបក្សកុម្មុយនីស្ដវៀតណាម និងជាប្រធានសហព័ន្ធនារីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្ដែងការគួរសម និងសវនាការ

-អនុញ្ញាតជូនឯកឧត្តម Thach Du ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងសវនាការ ព្រមទាំងជម្រាបលា

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម១រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អនុញ្ញាតជូនឯកឧត្តម **លីវ យុនសាន** សមាជិកគណៈអចិន្ត្រៃយ៍ នៃការិយាល័យនយោបាយ នៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តចិន និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតជូនលោក Qian zhimin ប្រធានក្រុមហ៊ុនសាជីវកម្មជាតិថាមពលនុយក្លេអ៊ែរចិន និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ

-អញ្ជើញជាអធិបតីក្នុងពិធីជប់លៀងជាកិត្តិយសជូនឯកឧត្តម **លីវ យុនសាន** សមាជិកគណៈអចិន្ត្រៃយ៍ នៃការិយាល័យនយោបាយ នៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តចិន នៅសណ្ឋាគារអាំងទែកុងទីណង់តាល់

-អញ្ជើញចុះស្តាប់សភាពការណ៍មូលដ្ឋាន និងជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌទាំង១២ នៃរាជធានីភ្នំពេញ

-អញ្ជើញជាអធិបតីក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៩ នៅវត្តអង្គបឹងចក សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-អញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធ បុព្វការីជន និងញាតិការទាំង៧សណ្តានរបស់សម្តេច នៅភូមិកណ្តាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញសាកសួរសុខទុក្ខ ឯកឧត្តម **អ៊ុំ ម៉ាន្នីរិន** និងឯកឧត្តម **អៀវ បណ្ណាការ** សមាជិកព្រឹទ្ធសភា ដែលមានជំងឺសម្រាកព្យាបាលនៅគេហដ្ឋាន

-អញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសព ឧបាសក **អ៊ុច ខុន** នៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៣៤ច្បាប់ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៣៤ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៣២ ទទួលសំណើពីរដ្ឋសភាចំនួន០២ និងជ្រាបជាព័ត៌មានចំនួន២៩ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតឲ្យឯកឧត្តម Marek Libricky ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឆេក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម

-អញ្ជើញជាអធិបតីក្នុងពិធីជប់លៀងជាកិត្តិយសក្នុងស្មារតីមិត្តភាព និងសាមគ្គីភាពដ៏ជិតស្និទ្ធជូន ឯកឧត្តម Wang Jiarui អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន នៅសណ្ឋាគារអ៊ិនធើខុនទីណង់តាល់ភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៩៨ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើកវេទិកាស្តីពី ស្ត្រី និងច្បាប់ នៅសាលសាលាខេត្តរតនគិរី និងវេទិកាថ្នាក់ខេត្តស្តីពី កិច្ចពិគ្រោះយោបល់សាធារណៈ និងពង្រឹងសមត្ថភាពការរៀបរកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន នៅសាលសាលាខេត្តប៉ៃលិន

-អញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍គណៈប្រតិភូសភា ប្រឹក្សានយោបាយប្រជាជនចិន ដឹកនាំដោយឯកឧត្តម Wang Jiarui អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ដែលអញ្ជើញមកបំពេញទស្សនកិច្ចសិក្សាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជូនដំណើរឯកឧត្តម Wang Jiarui និងគណៈប្រតិភូ អញ្ជើញទៅទស្សនកិច្ចខេត្តសៀមរាប នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ

-អញ្ជើញជាអធិបតីក្នុងពិធីបើកការប្រកួតបាល់ទាត់មិត្តភាព រវាងក្រុមបាល់ទាត់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាមួយក្រុមយុវជនខេត្តប៉ៃលិន ព្រមទាំងបានឧបត្ថម្ភសម្ភារៈកីឡាមួយចំនួនដល់ក្រុមទាំងពីរផងដែរ

-អញ្ជើញពិនិត្យមើលការរៀបចំ និងការអភិវឌ្ឍ ព្រមទាំងបានជួបសំណេះសំណាលសួរសុខទុក្ខជាមួយប្រជាពលរដ្ឋ នៅតំបន់ប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ

-អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយជូនដល់កងកម្លាំងនគរបាលការពារព្រំដែនកម្ពុជា-ឡាវ នៃវរៈសេនាតូចការពារព្រំដែនគោក៧០១ នៅខេត្តស្ទឹងត្រែង

-អញ្ជើញចុះពិនិត្យមើលការសាងសង់សមិទ្ធផលក្នុងវត្តបឹងអំបិល និងវត្តភ្នំយ៉ាត ព្រមទាំងបានប្រគេនបច្ច័យសម្រាប់កសាងសមិទ្ធផលក្នុងវត្តទាំងពីរចំនួន២,៩០០ដុល្លារ ប្រគេនព្រះសង្ឃ និងឧបត្ថម្ភតាជី យាយជី ប្រជាពលរដ្ឋ និងកងកម្លាំង សរុបចំនួន ២,១៧០,០០០រៀល ព្រមទាំងវត្តមង្គលសួស្តីត្រែង ខេត្តប៉ៃលិន និងបានប្រគេនបច្ច័យចំនួន៥០០ដុល្លារ ឧបត្ថម្ភតាជី យាយជី១៥នាក់ ម្នាក់ៗទទួលបាន ៥០,០០០រៀល

-អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១២ និងនាំយកទេយ្យទានប្រគេនព្រះសង្ឃ និងចែកជូនចាស់ជរា កុមារកំព្រា ក្នុងវត្តនីមួយៗចំនួន០៣វត្ត គឺវត្តប្រាំបីមុំ វត្តប្រនៀងផ្អែម និងវត្តទេពប្រណម នៅខេត្តតាកែវ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២៦ច្បាប់ ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :**

ក្នុងខែកញ្ញានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៣.១.មុខងារតាមដានការអនុវត្តច្បាប់**

-អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពី ការអនុវត្តសិទ្ធិមនុស្ស (សិទ្ធិប្រកបរបរនេសាទសមុទ្រ និងការបង្កើតសហគមន៍ប្រជានេសាទ) និងការដោះស្រាយពាក្យបណ្តឹងរបស់ថ្នាក់ក្រោមជាតិ នៅខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ ។

**៣.២.មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៦ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន០៦ករណី និងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន២២ករណី

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ រៀបចំវេទិកាថ្នាក់ខណ្ឌស្តីពី ការផ្តល់សេវាសាធារណៈ និងការចូលរួមរបស់មហាជនក្នុងការអភិវឌ្ឍមូលដ្ឋានភូមិ សង្កាត់ និងពិធីសម្ពោធស្រះទឹកត្រពាំងធំ ដាក់ជូនប្រជាពលរដ្ឋឲ្យប្រើប្រាស់ជាផ្លូវការ នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ រៀបចំវេទិកាថ្នាក់ខេត្តស្តីពី កិច្ចពិគ្រោះយោបល់សាធារណៈ និងពង្រឹងសមត្ថភាពការងារកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាននៅខេត្តប៉ៃលិន

-អញ្ជើញចូលរួមសហការជាមួយក្រុមសភាជាតិរៀបចំកិច្ចប្រជុំ (APF) តំបន់អាស៊ីប៉ាស៊ីហ្វិចលើកទី៨ នៅខេត្តព្រះសីហនុ

-អញ្ជើញចូលរួមស្តាប់បទបង្ហាញឯកសារស្រាវជ្រាវស្តីពី រដ្ឋបាលឃុំ សង្កាត់ សេវាសាធារណៈនៅមូលដ្ឋាន ការទំនាក់ទំនង និងផែនការអភិវឌ្ឍន៍ របស់វិទ្យាស្ថានសភាកម្ពុជា

-អញ្ជើញចូលរួមប្រជុំរវាងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា- ឡាវ ជាមួយតំណាងក្រសួងពាក់ព័ន្ធ និងតំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាអំពីការត្រៀមទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូក្រុមមិត្តភាពឡាវ-កម្ពុជា

-អញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងឆ្នាំ២០១៣-២០១៧ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងឆ្នាំ២០១៧-២០២២ រវាងសមាគមនារីវៀតណាម ជាមួយសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍ

-អញ្ជើញចូលរួមធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធតួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភាដល់មន្ត្រីមកពីសភាប្រទេសឡាវ ភូមា ថៃ និងកម្ពុជា ចំនួន១៤នាក់

សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន១៩៣លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៩លើក ។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ **មាន សំអាន** លោកជំទាវ **ពុំ ស៊ីចាន់** ឯកឧត្តម **អាំ សំអាត** និងឯកឧត្តម **ទួន សាមិន** អញ្ជើញបំពេញទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកការងារសង្គម និងវប្បធម៌របស់សភាតំបន់អាស៊ី(APF) នៅទីក្រុងធីមភូ ព្រះរាជាណាចក្រ

ប៊ូតាន និងចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៣៨ នៅទីក្រុងម៉ានីល នៃសាធារណរដ្ឋហ្វីលីពីន

-ឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញចូលរួមសន្និសិទស្តីពី លំនៅដ្ឋាន និងការអភិវឌ្ឍនគរូបនីយកម្ម នៅទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន និងបានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចជាផ្លូវការនៅប្រទេសសិង្ហបុរី ដើម្បីសិក្សាឈ្វេងយល់អំពីការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ

-អនុញ្ញាតឲ្យលោកស្រី **អាន ឡង់** Anne Lange អគ្គនាយិកាប្រតិភូសភាសហគមន៍បារាំងវ៉ាឡូនីប្រ៊ុចសែលប្រចាំការអមស្ថានទូតវៀតណាម និងទទួលបន្ទុកបន្ថែមផ្នែកអប់រំនៅកម្ពុជា និងឡាវ និងសហការីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អនុញ្ញាតឲ្យភ្ញៀវជនជាតិជប៉ុន លោក **Katsunori Yamamoto** និងលោក **Ikedo Yoshiki** ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគនៅកម្ពុជា ។៕

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូនៈ
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ